ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ...

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការគ្រប់គ្រង ការងារសិក្សាគំរោងប្លង់ រួមទីតាំង នៃស្ថាបត្យកម្ម និងប្លង់សាងសង់វិមានយុត្តិធម៌ នៃព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-យោងតាមការចាំបាច់

## សម្រេច

**ប្រការ១.-**

បង្កើតគណៈកម្មការគ្រប់គ្រងការងារសិក្សាគំរោងប្លង់រួមទីតាំងនៃស្ថាបត្យកម្ម និងប្លង់សាងសង់វិមានយុត្តិធម៌ នៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម ÷

១-ឯកឧត្តម **យឹម ណុលឡា** ទីប្រឹក្សារាជរដ្ឋាភិបាល ប្រធាន

| | | |
|---|---|---|
| ២-ឯកឧត្តម **ឆី យ៉ោន** | អនុប្រធាន ក្រុមសង្កេតការណ៍ សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ | អនុប្រធាន |
| ៣-ឯកឧត្តមបណ្ឌិតរដ្ឋ **តិច សំណាង** | អគ្គលេខាធិការនៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា | សមាជិក |
| ៤-ឯកឧត្តម **អ៊ុក សុមេត្ត** | អគ្គនាយករង អាជ្ញាធរអប្សរា | សមាជិក |
| ៥-ឯកឧត្តម **ម៉ម សុផារ៉ាណា** | អនុរដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | សមាជិក |
| ៦-លោក **ហ៊ុយ ណារ៉ា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានសំណង់ | សមាជិក |
| ៧-លោក **ឆាយ ឫទ្ធិសែន** | អនុប្រធានមន្ទីរ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ | សមាជិក |

**ប្រការ២.-**

គណៈកម្មការនេះមានភារកិច្ចដូចខាងក្រោម :

-គ្រប់គ្រង និងដឹកនាំការងារសិក្សាគំរោងប្លង់រួមទីតាំងនៃស្ថាបត្យកម្ម និងគំរោងប្លង់បច្ចេកទេសសាងសង់វិមានយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា ។

-តាមដាន ត្រួតពិនិត្យ និងជំរុញដំណើរការការងារខាងលើតាមដំណាក់កាល ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាលជាពតិមាន និង ពិនិត្យសំរេច ។

-ធ្វើទំនាក់ទំនងជាមួយបណ្ដាក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីប្រមូលពតិមានចាំបាច់សំរាប់បំរើអោយការងារសិក្សាខាងលើទទួលបានសំរេចលទ្ធផលល្អប្រសើរ ។

-ធ្វើការគណនាតំលៃនៃការចំណាយ សំរាប់ការងារសាងសង់នេះទាំងមូល ដើម្បីលើកជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

**ប្រការ ៣.-**

គណៈកម្មការមានសិទ្ធិបង្កើតក្រុមសិក្សាគំរោងប្លង់ស្ថាបត្យកម្ម និង ប្លង់បច្ចេកទេសសាងសង់ តាមតម្រូវការ ដើម្បីធានាអោយបានសំរេចភារកិច្ចខាងលើ ទាន់ពេលវេលាតាមការកំណត់ ។

**ប្រការ ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី

-ដូចប្រការ៤

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ